រៀបចំដោយ

គាំទ្រដោយ

ព្រឹត្តិបត្រពាណិជ្ជកម្ម
iTrade Bulletin

Inside

infographic

“ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម កម្ពុជា និងអេមីរ៉ាតអារ៉ាប់រួម”

“Cambodia- United Arab Emirates (UAE) Trade Statistics and Facts”

វ៉ុល ០១ | លេខ ០៤ | ខែឧសភា ឆ្នាំ២០២៥
VOLUME 01 | ISSUE 04 | MAY 2025

ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម កម្ពុជា និងអេមីរ៉ាតអារ៉ាប់រួម

ផ្នែកទី ០១

រៀបចំដោយ

គាំទ្រដោយ

សូមស្កេនដើម្បីទាញយកព្រឹត្តិបត្រពាណិជ្ជកម្ម

** ព័ត៌មានបន្ថែម
សូមទាក់ទងមកកាន់លេខទូរស័ព្ទទំនាក់ទំនងសាធារណៈ: ១២៦៦

សារតារ នៃកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងកម្ពុជា និងអេមីរ៉ាតអារ៉ាប់រួម

០១

១២/តុលា/២០២២

កម្ពុជា និងអេមីរ៉ាតអារ៉ាប់រួមបានចុះហត្ថលេខាលើលក្ខន្តិកៈយោងនៃការបង្កើតកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងកម្ពុជា និងអេមីរ៉ាតអារ៉ាប់រួមនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២

០២

២៤-២៦/តុលា/២០២២

ការចរចាជុំទី១ នៅថ្ងៃទី២៤-២៦ ខែតុលា ឆ្នាំ២០២២ នៅរដ្ឋធានីអាប៊ុយដាប៊ី អេមីរ៉ាតអារ៉ាប់រួម

០៣

១៩-២១/ធ្នូ/២០២២

ការចរចាជុំទី២ នៅថ្ងៃទី១៩-២១ ខែធ្នូ ឆ្នាំ២០២២ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

០៤

២០-២២/កុម្ភៈ/២០២៣

ការចរចាជុំទី៣(ជុំចុងក្រោយ) នៅថ្ងៃទី២០-២២ ខែកុម្ភៈ ឆ្នាំ២០២៣ នៅទីក្រុងឌុយបៃ ប្រទេសអេមីរ៉ាតអារ៉ាប់រួម

០៥

មិថុនា/០៨/២០២៣

កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងកម្ពុជា និងអេមីរ៉ាតអារ៉ាប់រួម បានចុះហត្ថលេខានៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៣

០៦

មករា/៣១/២០២៤

កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងកម្ពុជា និងអេមីរ៉ាតអារ៉ាប់រួមបានចូលជាធរមាននៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤

ច្រកទីផ្សារអេមីរ៉ាតអារ៉ាប់រួម

កម្ពុជាអាចទទួលបានភាពអនុគ្រោះអត្រាពន្ធសម្រាប់ការនាំចេញទៅកាន់អេមីរ៉ាតអារ៉ាប់រួមក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- ទទួលបានពន្ធអនុគ្រោះក្រោមកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងកម្ពុជា និងអេមីរ៉ាតអារ៉ាប់រួមប្រមាណ៖ ៩៧,៨0% នៃបន្ទាត់ពន្ធគយសរុប ៧៨៥៦
- ទំនិញដែលអាចនាំចេញទៅកាន់ទីផ្សារអេមីរ៉ាតអារ៉ាប់រួមជាមួយពន្ធគយ 0%

មុខទំនិញកសិកម្ម

- អង្ករ
- ដំឡូងមី
- គ្រាប់ស្វាយចន្ទី
- ម្រេច
- គ្រាប់កាហ្វេ
- បន្ទះខ្លឹមចន្ទន៍
- សត្វរស់:
  - ›ទា
  - ›ក្ងាន
  - ›សេះ
  - ›ទន្សាយ
- សាច់សត្វ:
  - ›គោ
  - ›ក្របី
  - ›ពពែ
  - ›សេះ
  - ›ត្រី
  - ›អន្ទង់
  - ›ក្ដាម
  - ›បង្កង
  - ›ព្រុយត្រី
- បន្លែ:
  - ›ផ្សិត
  - ›ត្រសក់
  - ›ខ្ទឹម
  - ›ស្ពៃ
  - ›ការ៉ុត
  - ›ពោត
- ផ្លែឈើ:
  - ›ចេក
  - ›ត្របែក
  - ›ស្វាយ
  - ›ក្រូច
  - ›ឪឡឹក
  - ›ទុរេន ។ល។

មុខទំនិញឧស្សាហកម្ម

- កង់
- បន្ទះសូឡា
- គ្រឿងបង្គុំអេឡិចត្រូនិក
- រថយន្តអគ្គិសនី
- មុខទំនិញវាយនភ័ណ្ឌរួមមានកាបូបធ្វើដំណើរ
- ស្បែកជើង
- សម្លៀកបំពាក់
- កម្រាលព្រំ
- ក្រណាត់សូត្រ
- ប្រេងឥន្ធនៈ
- ហ្គាស
- សារធាតុគីមី
- ផលិតផលប្លាស្ទិក
- កៅស៊ូ (Latex)
- សម្ភារៈធ្វើពីកញ្ចក់
- គ្រឿងម៉ាស៊ីន ។ល។

មុខទំនិញកែច្នៃ

- គ្រឿងកំប៉ុងម្ហូបអាហារ អាហារកែច្នៃពីអង្ករ:
  - ›គុយទាវ
  - ›នំក្រៀម
  - ›នំស្រួយផលិតពីអង្ករ
- ប្រភេទទំនិញកសិកម្មកែច្នៃ:
  - ›សំបុកត្រចៀកកាំ
  - ›ទំនិញកែច្នៃពីត្រី
  - ›ផ្លែមៀន
  - ›ទំនិញកែច្នៃពីដូង
  - ›ដំណាប់ផ្លែឈើជាដើម
- ទំនិញផ្សេងទៀតរួមមាន:
  - ›ប្រេងឆា
  - ›លោហៈនិងថ្ម
  - ›ម្សៅធ្វើការ៉េម ។ល។

- ប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មផ្ដល់ក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក

ទិដ្ឋភាពទូទៅនៃសេដ្ឋកិច្ចរបស់អេមីរ៉ាតអារ៉ាប់រួមនៅឆ្នាំ ២០២៤*

ផលិតផលក្នុងស្រុកសរុប(ផ.ស.ស): ៥៣៧,០៨ ប៊ីលានដុល្លារ

ផ.ស.ស សម្រាប់មនុស្សម្នាក់: ៤៨,៨៣ ពាន់ដុល្លារ

ប្រជាជនសរុប: ១១ លាននាក់

ទំហំពាណិជ្ជកម្ម: ៦០៩,៥១ ប៊ីលានដុល្លារ**

តួលេខពាណិជ្ជកម្ម***

ពាណិជ្ជកម្មទ្វេភាគីកម្ពុជា-អេមីរ៉ាតអារ៉ាប់រួម

២០២៣	៨៦,៨០ លានដុល្លារ
២០២៤	៩១,១៤ លានដុល្លារ

អត្រាកំណើនពាណិជ្ជកម្ម ៖ ៥%

ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម កម្ពុជា និងអេមីរ៉ាតអារ៉ាប់រួម

ផ្នែកទី ០២

ពាណិជ្ជកម្មនាំចេញ-នាំចូល

- **កម្ពុជានាំចេញទៅអេមីរ៉ាតអារ៉ាប់រួម**

២០២៣	៧០,៩៨ លានដុល្លារ
២០២៤	៦៧,៧៨ លានដុល្លារ



អត្រាកំណើននៃការនាំចេញ៖ -៤,៥២%

- **កម្ពុជានាំចូលពីអេមីរ៉ាតអារ៉ាប់រួម**

២០២៣	១៥,៨១ លានដុល្លារ
២០២៤	២៣,៣៦ លានដុល្លារ

អត្រាកំណើននៃការនាំចូល៖ ៤៧,៧៣%

មុខទំនិញសំខាន់ៗនាំចេញ និងនាំចូលនៅឆ្នាំ២០២៤

- **នាំចេញទៅអេមីរ៉ាតអារ៉ាប់រួម**

1. កូដទំនិញ: ៦១
2. កូដទំនិញ: ៦៤
3. កូដទំនិញ: ៦២
4. កូដទំនិញ: ៤២
5. កូដទំនិញ: ៩៤

កូដទំនិញ: ៦១

សម្លៀកបំពាក់ និងគ្រឿងបន្ទាប់បន្សំ ដែលធ្វើឡើងពីក្រណាត់ចាក់ដោយម្ជុលពីរ ឬមួយ៖ ៣៦.៨៩៦ ពាន់ដុល្លារ

កូដទំនិញ: ៦៤

ស្បែកជើង ស្រោមជើង និងវត្ថុប្រហាក់ប្រហែល; ភាគរបស់វត្ថុទាំងនេះ៖ ១៥.៣២៦ ពាន់ដុល្លារ

កូដទំនិញ: ៦២

សម្លៀកបំពាក់ និងគ្រឿងបន្ទាប់បន្សំនៃសម្លៀក បំពាក់មិនធ្វើឡើងពីការចាក់ដោយម្ជុលពីរ ឬមួយ៖ ៨.៤៦៣ពាន់ដុល្លារ

កូដទំនិញ: ៤២

វត្ថុធ្វើអំពីស្បែក; បរិក្ខារធ្វើពីរោមសត្វ បរិក្ខារបំពាក់ កែបសេះ បង្ហៀរសេះ គ្រឿងប្រដាប់សម្រាប់ការធ្វើ ដំណើរ កាបូបដៃ និងវត្ថុសម្រាប់វេចខ្ចប់ ប្រហាក់ ប្រហែល; វត្ថុធ្វើពីពោះវៀនសត្វ (ក្រៅពីវត្ថុធ្វើពីសូត្រដង្កូវនាង)៖ ៣.៩០៣ ពាន់ដុល្លារ

កូដទំនិញ: ៩៤

គ្រឿងសង្ហារឹម; សម្ភារគ្រែ ពូក ទម្រពូក ខ្នើយកល់ និង វត្ថុប្រហាក់ប្រហែល; អំពូល និងជើងអំពូល មិនមានចែង ឬរាប់បញ្ចូលនៅទីតាំងផ្សេងទៀត; ផ្លាកសញ្ញាមានភ្លើងបំភ្លឺ ផ្លាកឃីហោមានភ្លើងបំភ្លឺ និងវត្ថុប្រហាក់ប្រហែល; សំណង់គ្រោងរួច៖ ២៨១ ពាន់ដុល្លារ

- **នាំចូលពីអេមីរ៉ាតអារ៉ាប់រួម**

1. កូដទំនិញ: ៣៩
2. កូដទំនិញ: ២៧
3. កូដទំនិញ: ២៤
4. កូដទំនិញ: ៩៤
5. កូដទំនិញ: ៦៩

កូដទំនិញ: ៣៩

វត្ថុធាតុប្លាស្ទិក និងវត្ថុធ្វើពីប្លាស្ទិក កៅស៊ូ និងវត្ថុធ្វើពីកៅស៊ូ៖ ៦.០៦៣ ពាន់ដុល្លារ

កូដទំនិញ: ២៧

រ៉ែប្រើជាគ្រឿងចំហេះ ប្រេងខនិជ និងផលិតផលពីការចម្រាញ់របស់វា; កៅស៊ូប៊ីទីម; ក្រមួនរ៉ែ៖ ៨.៤៦៤ពាន់ដុល្លារ

កូដទំនិញ: ២៤

ថ្នាំជក់ និងផលិតផលជំនួសឲ្យថ្នាំជក់៖ ៥.៥៩១ ពាន់ដុល្លារ

កូដទំនិញ: ៩៤

គ្រឿងសង្ហារឹម; សម្ភារគ្រែ ពូក ទម្រពូក ខ្នើយកល់ និង វត្ថុប្រហាក់ប្រហែល; អំពូល និងជើងអំពូល មិនមានចែង ឬរាប់បញ្ចូលនៅទីតាំងផ្សេងទៀត; ផ្លាកសញ្ញាមានភ្លើងបំភ្លឺ ផ្លាកឃីហោមានភ្លើងបំភ្លឺ និងវត្ថុប្រហាក់ប្រហែល; សំណង់គ្រោងរួច៖ ៤៥៦ ពាន់ដុល្លារ

កូដទំនិញ: ៦៩

ផលិតផលធ្វើពីសេរ៉ាមិក៖ ១៣៩ ពាន់ដុល្លារ

ប្រភព: *IMF (https://www.imf.org/external/datamapper/profile/ARE (16/05/2025))
**Trademap (www.trademap.org(16/05/2025))
***អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា(https:/stats.customs.gov.kh/)

រៀបចំដោយ **គាំទ្រដោយ**

សូមស្កេនដើម្បីទាញយក ព្រឹត្តបត្រពាណិជ្ជកម្ម

** ព័ត៌មានបន្ថែម
សូមទាក់ទងមកកាន់លេខទូរស័ព្ទទំនាក់ទំនងសាធារណៈ: ១២៦៦

Cambodia- United Arab Emirates (UAE) Trade Statistics and Facts

Organized by   Supported by

Scan to access iTrade Bulletin

** For more information, please contact the Ministry of Commerce Call center 1266

Part 01

Background of Cambodia -UAE Comprehensive Economic Partnership Agreement

01 Oct/12/2022
Cambodia-UAE signed the reference status of the Cambodia-UAE CEPA on October 12, 2022

02 Oct/24-26/2022
The 1st Round of Negotiations on October 24-26, 2022 in Abu Dhabi, United Arab Emirates

03 Dec/19-21/2022
The 2nd Round of Negotiations on 19-21 December 2022 in Phnom Penh, Kingdom of Cambodia

04 Feb/20-22/2023
The 3rd Round of Negotiations (Final Round) on 20-22 February 2023 in Dubai, United Arab Emirates

05 Jun/08/2023
Cambodia-UAE CEPA signed on June 8, 2023 in Phnom Penh, Kingdom of Cambodia

06 Jan/31/2024
Cambodia-UAE CEPA entered into force on January 31, 2024

UAE MARKET ACCESS

Cambodia can get preferential tariffs on exports to UAE under the following condition:

- Received preferential tariffs under Cambodia -UAE Comprehensive Economic Partnership Agreement on approximately: 97.80% of the total tariff lines 7856

Products that can be exported to the UAE market with 0% tariffs:

AGRICULTURAL PRODUCTS
- Rice
- Cassava
- Cashew nuts
- Pepper
- Coffee beans
- Agarwood
- Live animals:
  - Ducks
  - Geese
  - Horses
  - Rabbits
- Meat:
  - Cows
  - Buffaloes
  - Goats
  - Horses
  - Fish
  - Eels
  - Crabs
  - Lobsters
  - Fish fins
- Vegetables:
  - Mushrooms
  - Cucumbers
  - Garlic
  - Cabbage
  - Carrots
  - Corn
- Fruits:
  - Bananas
  - Guava
  - Mangoes
  - Oranges
  - Watermelons
  - Durians, etc.

MANUFACTURING PRODUCTS
- Bicycles
- Solar panels
- Electronic compo
- Nents
- Electric vehicles
- And textile products
- Including travel bags
- Shoes
- Clothing
- Carpets
- Silk fabrics
- Fuel
- Gas
- Chemicals
- Plastic products
- Rubber (latex)
- Glass materials
- Machinery, etc.

PROCESSED PRODUCTS
- Canned food processed rice foods:
  - Noodles
  - Crackers
  - Rice crackers
- Processed agricultural goods:
  - Beetle nests
  - Processed fish products
  - Mangoes
  - Processed coconut products
  - Fruit pulp, etc
- And other products including:
  - Cooking oil
  - Metals
  - Stones
  - Ice-cream powder, etc.

- The Generalized System of Preferences under the WTO agreements.

UAE ECONOMIC OVERVIEW IN 2024*

GDP: USD 537.08 Billion

GDP per capita: USD 48.83 thousand**

Total Population: 11 Million

Trade Volume: USD 609.51 Billion

BILATERAL TRADE***

Cambodia- United Arab Emirates Bilateral Trade

2023 USD 86.80 million

2024 USD 91.14 million

Trade Growth Rate: 5%

Cambodia- United Arab Emirates (UAE) Trade Statistics and Facts Part 02

TRADE EXPORT-IMPORT

- **Cambodia exports to UAE**

  2023 USD 70.98 million

  2024 USD 67.78 million

  Export Growth Rate: -4.52%

- **Cambodia imports from UAE**

  2023 USD 15.81 million

  2024 USD 23.36 million

  Import Growth Rate: 47.73%

MAIN GOODS OF IMPORT AND EXPORT IN 2024

- **Export to UAE**

Export to UAE

1. HS Code: 61
2. HS Code: 64
3. HS Code: 62
4. HS Code: 42
5. HS Code: 94

HS Code: 61

Articles of apparel and clothing accessories, knitted or crocheted: USD 36,896 Thousand

HS Code: 64

Footwear, gaiters and the like; parts of such articles: USD 15,326 Thousand

HS Code: 62

Articles of apparel and clothing accessories, not knitted or crocheted: USD 8,463 Thousand

HS Code: 42

Articles of leather; saddlery and harness; travel goods, handbags and similar containers; articles of animal gut (other than silk-worm gut): USD 3,903 Thousand

HS Code: 94

Furniture; bedding, mattresses, mattress supports, cushions and similar stuffed furnishings; lamps and lighting fittings, not elsewhere specified or included; illuminated signs, illuminated name-plates and the like; prefabricated buildings. : USD 281 Thousand

- **Import from UAE**

Import from UAE

1. HS Code: 39
2. HS Code: 27
3. HS Code: 24
4. HS Code: 94
5. HS Code: 69

HS Code: 39

Plastics and articles thereof: USD 6,063 Thousand

HS Code: 27

Mineral fuels, mineral oils and products of their distillation; bituminous substances; mineral waxes: USD 8,464 Thousand

HS Code: 24

Tobacco and manufactured tobacco substitutes: USD 5,591 Thousand

HS Code: 94

Furniture; bedding, mattresses, mattress supports, cushions and similar stuffed furnishings; lamps and lighting fittings, not elsewhere specified or included; illuminated signs, illuminated name-plates and the like; prefabricated buildings: USD 456 Thousand

HS Code: 69

Ceramic products: USD 139 Thousand

Source: *IMF (https://www.imf.org/external/datamapper/profile/ARE (16/05/2025))
**Trademap (www.trademap.org(16/05/2025))
***General Department of Customs and Excise (https://stats.customs.gov.kh/)

Organized by

Supported by

Scan to access iTrade Bulletin

** For more information, please contact the Ministry of Commerce Call center 1266

ពាណិជ្ជកម្មកម្ពុជា-ចិនកើនដល់៥,៦ ប៊ីលានដុល្លារក្នុងរយៈពេល ៤ខែ ដំបូងនៃឆ្នាំ២០២៥

ទំហំពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងចិនបានកើនឡើងដល់ជាង៥,៦ ប៊ីលានដុល្លារ ក្នុងរយៈពេល៤ខែដំបូង នៃឆ្នាំ២០២៥ ដែលមានការកើនឡើងប្រមាណ២៧% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន នេះបើយោងតាមរបាយការណ៍ចេញថ្មីពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។ ទិន្នន័យពាណិជ្ជកម្មចុងក្រោយបង្អស់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបង្ហាញពីទំហំពាណិជ្ជកម្មសរុបរវាងប្រទេសទាំងពីរ បានឈានដល់ ៥,៦៩ប៊ីលានដុល្លារ ចាប់ពីខែមករា ដល់ខែមេសា ឆ្នាំ២០២៥ គឺកើនឡើងពី៤,៤៨ ប៊ីលានដុល្លារ ក្នុងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៤។ ទោះជាយ៉ាងណា ការនាំចេញរបស់កម្ពុជាទៅចិនបានធ្លាក់ចុះបន្តិចប្រមាណ១,៧% ធៀបនឹងឆ្នាំមុន ដែលមានទំហំសរុប ៤៧៨,៦៣ លានដុល្លារ។ ផ្ទុយទៅវិញ ការនាំចូលពីចិនបានកើនឡើងយ៉ាងខ្លាំងប្រមាណ៣០,៥% រហូតដល់៥,២១ ប៊ីលានដុល្លារ។ ប្រភព៖ Khmer Times

កម្ពុជាត្រៀមរៀបចំពិព័រណ៍ចិន-អាស៊ាន លើកទី២២

ឯកឧត្តម ទិត សីច័ន្ទលី អគ្គនាយក នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម និងជាសហអគ្គលេខាធិការរងនៃលេខាធិការដ្ឋានពិព័រណ៍ចិន-អាស៊ាន បានដឹកនាំក្រុមការងារបច្ចេកទេសកម្ពុជា ចូលរួមកិច្ចប្រជុំជាមួយមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដើម្បីត្រៀមលក្ខណៈរៀបចំ និងចូលរួមពិព័រណ៍ចិន-អាស៊ាន លើកទី២២ ឆ្នាំ២០២៥។ កិច្ចប្រជុំនេះបានធ្វើឡើងនាទីក្រុងណាននីង ប្រទេសចិន ដែលដឹកនាំដោយឯកឧត្តម Wang Qihui អគ្គនាយករង នៃអគ្គនាយកដ្ឋានកិច្ចការអាស៊ី នៃក្រសួងពាណិជ្ជកម្មចិន និងឯកឧត្តម Htein Lynn អគ្គនាយកអង្គភាពជំរុញពាណិជ្ជកម្មមីយ៉ាន់ម៉ា។ ការពិភាក្សាផ្តោតលើការបញ្ចប់ផែនការការងារទាំងមូល សម្រាប់ការរៀបចំតាំងពិព័រណ៍នាពេលខាងមុខ រួមទាំងការជ្រើសរើសទីតាំងសម្រាប់សាងសង់ពន្លាជាតិ។ បន្ថែមពីនេះ កិច្ចប្រជុំនេះ ក៏ផ្តោតលើការពិនិត្យ និងពិភាក្សាលើវិស័យថ្មីៗ ដូចជា ថាមពលស្អាត បញ្ញាសិប្បនិម្មិត(AI) ពាណិជ្ជកម្មឌីជីថល និងស្វែងរកយន្តការដើម្បីពង្រឹង និងពង្រីកបន្ថែមនូវកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគ រវាងអាស៊ាន និងចិន ផងដែរ។ ប្រភព៖ Khmer Times

កម្ពុជាស្នើឱ្យប្រទេសជប៉ុនវិនិយោគលើតំបន់សេដ្ឋកិច្ចពិសេស

កម្ពុជា បានលើកទឹកចិត្តដល់ថ្នាក់ដឹកនាំក្រុមហ៊ុនផ្គត់ផ្គង់ឋយន្តយក្ស Yazaki របស់ជប៉ុន ស្វែងយល់ពីលទ្ធភាពនៃការវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ដើម្បីជួយទាក់ទាញអ្នកវិនិយោគជប៉ុនឱ្យកាន់តែច្រើនមកកាន់កម្ពុជា។ ក្នុងរយៈពេលបួនខែដំបូងនៃឆ្នាំ២០២៥ ទំហំពាណិជ្ជកម្មរវាងប្រទេសទាំងពីរមានចំនួនជាង៨៣២ លានដុល្លារ។ លោក Yoshimoto Ito នាយកប្រតិបត្តិរងក្រុមហ៊ុនYazaki បានជួបពិភាក្សាការងារជាមួយឯកឧត្តម ជា វុទ្ធី អគ្គលេខាធិការនៃគណៈកម្មការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា បានរាយការណ៍ថា ចាប់ពីខែមករា ដល់ខែមេសា ទំហំពាណិជ្ជកម្មរវាងកម្ពុជា និងជប៉ុន មានចំនួនសរុប៨៣២,២៩ លានដុល្លារ គឺកើនឡើង២៩,៧% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ កម្ពុជា បាននាំចេញទៅប្រទេសជប៉ុនចំនួន ៥២៣,៤៩ លានដុល្លារអាមេរិក(កើនឡើង១៩,៨%) ខណៈការនាំចូលមានចំនួន៣០៨,៨ លានដុល្លារ(កើនឡើង៥០,៦%)។ ផ្អែកលើតួលេខទាំងនេះ កម្ពុជា មានអតិរេកពាណិជ្ជកម្មចំនួន២១៤,៦៩ លានដុល្លារ ធៀបនឹង ២៣១,៨១ លានដុល្លារក្នុងរយៈពេលដូចគ្នានៃឆ្នាំ២០២៤។ ប្រភព៖ Phnom Penh Post

ការនាំចេញកៅស៊ូរបស់កម្ពុជាកើនឡើងជាលំដាប់ ទោះបីជាតម្រូវការក្នុងស្រុកកើនឡើង

ការនាំចេញជ័រកៅស៊ូ និងដើមកៅស៊ូបានធ្វើឱ្យកម្ពុជារកចំណូលបានជិត១៥០ លានដុល្លារ ចាប់ពីខែមករា ដល់ខែមេសា គឺកើនឡើងជាង១៨% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ការកើនឡើងនៃការនាំចេញសរុប ខណៈដែលតម្រូវការក្នុងស្រុកពីក្រុមហ៊ុនផលិតសំបកកង់ក៏បន្តកើនឡើងដែរ។ របាយការណ៍ពីអគ្គនាយកដ្ឋានកៅស៊ូ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្ហាញថា ចាប់ពីខែមករា ដល់ខែមេសា កម្ពុជាផលិតជ័រកៅស៊ូបាន ៨១.៩៦២ តោន ថយចុះ៥.១៧១ តោន ឬ៥,៩% បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៤។ កម្ពុជាបាននាំចេញជ័រកៅស៊ូចំនួន ៧៦.៤៦៧ តោន ធ្លាក់ចុះ ៨.៩៦១ តោន ឬ ១០,៥% បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៤ និងរកចំណូលបាន ១៤៨,១៨ លានដុល្លារពីជ័រកៅស៊ូ និង១,៦៩លានដុល្លារ ពីដើមកៅស៊ូ (៦.៩២៩ ម៉ែត្រគូប)។ ប្រភព៖ Phnom Penh Post

Cambodia-China Trade Touches $5.6 Billion in Four Months

Bilateral trade between Cambodia and China surged past $5.6 billion in the first four months of 2025, marking a robust 27 percent increase compared to the same period last year, according to a recent report from the General Department of Customs and Excise (GDCE). The GDCE's latest trade data shows total trade volume between the two countries reached $5.69 billion from January to April 2025, up from $4.48 billion during the corresponding period in 2024. Cambodian exports to China, however, saw a slight dip of 1.7 percent year-on-year, totalling $478.63 million. In contrast, imports from China jumped significantly by 30.5 percent, reaching $5.21 billion. ***Source: Khmer Times***

Cambodia Gears Up For 22nd China-ASEAN Expo

Tith Seychanly, Director-General of the General Directorate of Trade Promotion within the Ministry of Commerce (MoC), led the Cambodian technical delegation to the Senior Officials' Meeting in preparation for the 22nd China-Asean Expo 2025. The meeting took place in Nanning, China, and was co-chaired by Wang Qihui, Deputy Director-General of the Department of Asian Affairs of China's Ministry of Commerce, and Dr HteinLynn, Director-General of the Myanmar Trade Promotion Organisation. Discussions focussed on finalising the overall work plan for the upcoming expo, including the allocation of the "Cities of Charm" pavilions. The meeting also covered emerging sectors such as clean energy, artificial intelligence, and digital trade—highlighting efforts to deepen Asean-China economic, trade, and investment cooperation. ***Source: Khmer Times***

Cambodia Proposes Japanese SEZ Investment

Cambodia has encouraged the leadership of giant Japanese automotive supplier Yazaki group to explore the possibility of investing in special economic zones to help attract more Japanese investors to the Kingdom. In the first four months of 2025, trade between the two nations equalled more than $832 million. Yoshimoto Ito, deputy CEO of Yazaki, met with Chea Vuthy, secretary-general of the Cambodian Investment Board under the Council for the Development of Cambodia. The General Department of Customs and Excise (GDCE) reported that from January to April, trade between Cambodia and Japan totalled $832.29 million, an increase of 29.7% over the same period last year. Cambodia exported $523.49 million to Japan (up 19.8%), while imports stood at $308.8 million (up 50.6%). Based on these figures, Cambodia has a trade surplus of $214.69 million, compared to $231.81 million in the same period of 2024.
Source: Phnom Penh Post

Cambodian Rubber Export Earnings Up As; Even as Domestic Demand Grows

The export of rubber latex and rubberwood saw Cambodia earn nearly $150 million from Jan-Apr, a rise of over 18% compared to the same period last year. The increased total comes as domestic demand from tyre manufacturing companies continues to grow. A recent report from the General Directorate of Rubber – under the Ministry of Agriculture, Forestry, and Fisheries – showed that from January to April, Cambodia produced 81,962 tonnes of rubber latex, a decrease of 5,171 tons or 5.9% compared to the same period in 2024. The Kingdom exported 76,467 tonnes of rubber latex, a decline of 8,961 tons or 10.5% compared to the same period in 2024, generating revenue of $148.18 million from latex and $1.69 million from rubberwood (6,929 cubic metres).
Source: Phnom Penh Post

ការថយមួយជំហានពីជម្លោះសេដ្ឋកិច្ចសកល

កិច្ចព្រមព្រៀងពាណិជ្ជកម្មថ្មីរវាងអាម៉េរិក និងចិនបានកាត់បន្ថយពន្ធគយយ៉ាងច្រើន ដោយបន្ធូរភាពតានតឹងសេដ្ឋកិច្ចសកល បន្ទាប់ពីមានវិបត្តិនយោបាយថ្មីៗ។ កិច្ចព្រមព្រៀងនេះរួមមានការកាត់បន្ថយពន្ធគយមកត្រឹមតែ៣០% លើការនាំចេញរបស់ចិន និង១០% លើការនាំចេញរបស់អាម៉េរិកទៅកាន់ប្រទេសចិន ដែលមានប្រសិទ្ធភាពរយៈពេល៩០ថ្ងៃ។ នេះរួមជាមួយនឹងការផ្អាកពន្ធលើប្រទេសផ្សេងទៀត បានធ្វើឱ្យទីផ្សារមានស្ថិរភាព។ ទោះយ៉ាងណា ភាពមិនច្បាស់លាស់ខាងសេដ្ឋកិច្ចនៅតែមានកម្រិតខ្ពស់។ មូលនិធិរូបិយវត្ថុអន្តរជាតិ បានបន្ថយការព្យាករកំណើនសកលមកត្រឹម២,៨%។ ទោះបីជា ស្ថានភាពទីផ្សារបានធូរស្រាលក៏ដោយ ក៏សេដ្ឋកិច្ចសកលនៅតែប្រឈមមុខនឹងបញ្ហា រួមទាំងការកើនឡើងនៃបំណុល និងការធ្លាក់ចុះតម្រូវការនៃអ្នកប្រើប្រាស់។ ប្រភព៖ World Economic Forum

កំណត់ឡើងវិញនូវហានិភ័យនៅ ក្នុងយុគសម័យថាមវន្តនៃពាណិជ្ជកម្មសកល

នៅក្នុងបរិបទពាណិជ្ជកម្មសកល កាន់តែជាប់គាំងជាមួយនឹងសម្ពាធសេដ្ឋកិច្ច និងភូមិសាស្ត្រនយោបាយ អ្នកជំនាញផ្នែកពាណិជ្ជកម្មត្រូវពិនិត្យមើលកត្តាហានិភ័យផ្នែកសំខាន់ៗ នៃលំហូរការងារនាំចូល និងនាំចេញ និងខ្សែប្រវាក់ផ្គត់ផ្គង់សកល។ បច្ចុប្បន្ននេះ ហានិភ័យទីមួយគឺ រលកពន្ធគយ ជាពិសេសការប្រឆាំងនឹងការនាំចូលរបស់ចិន កំពុងពន្លឿនការបែកខ្ញែក និងការកើនឡើងនៃថ្លៃដើមទំនិញ។ អ្នកនាំចូលត្រូវតែសិក្សាអំពីគម្រូពន្ធគយ និងសម្របតាមយុទ្ធសាស្ត្រក្នុងការផ្លាស់ប្តូរពន្ធគយ។ វិធានការសំខាន់ៗ រួមមាន៖ ការវិភាគប្រកពាណិជ្ជកម្ម, ការផ្ទៀងផ្ទាត់អ្នកផ្គត់ផ្គង់, ការផ្ទៀងផ្ទាត់ឯកសារបញ្ជាក់ប្រភពដើមទំនិញ ការយល់ដឹងអំពីហានិភ័យពីដៃគូជារឿងសំខាន់។ តំបន់ពាណិជ្ជកម្មសេរីផ្តល់អត្ថប្រយោជន៍ តែក៏មានហានិភ័យ ក្រៅពីបច្ចេកវិទ្យាអាម៉េរិក រួមមានទិន្នន័យជាក់ស្តែង ការកំណត់អត្តសញ្ញាណជីវមាត្រ និងការផ្ទៀងផ្ទាត់ឯកសារ មានសារៈសំខាន់ណាស់ក្នុងការធានាឱ្យមានតម្លាភាព និងច្បាស់លាស់។

ប្រភព៖ *THOMSONREUTERS*

បួនចំណុចត្រូវដឹងអំពីកិច្ចព្រមព្រៀងពាណិជ្ជកម្មអង់គ្លេស-ឥណ្ឌា

អង់គ្លេស និងឥណ្ឌា បានព្រមព្រៀងលើកិច្ចព្រមព្រៀងពាណិជ្ជកម្មដ៏សំខាន់មួយ ដើម្បីកាត់បន្ថយពន្ធលើទំនិញដូចជាសម្លៀកបំពាក់ ម្ហូបអាហារ គ្រឿងអលង្ការ រថយន្ត ស្រាវីស្គី និងឧបករណ៍វេជ្ជសាស្ត្រ។ ក្រុមហ៊ុនអង់គ្លេសក៏នឹងទទួលបានសិទ្ធិនៃកិច្ចសន្យាសេវាកម្មឥណ្ឌាផងដែរ។ ទោះបីជា កិច្ចព្រមព្រៀងនឹងមិនចូលជាធរមានភ្លាមៗ រដ្ឋាភិបាលអង់គ្លេសរំពឹងថាតម្លៃទំនិញនឹងចុះថោក អ្នកប្រើប្រាស់មានជម្រើសកាន់តែច្រើន និងកំណើនអាជីវកម្ម។ ពន្ធគយលើស្រាវីស្គីនៅក្នុងប្រទេសឥណ្ឌានឹងធ្លាក់ចុះពី១៥០% ទៅ ៤០% ក្នុងរយៈពេលដប់ឆ្នាំ ហើយពន្ធរថយន្តពីជាង ១00% ទៅ ១0% ។ កិច្ចព្រមព្រៀងនេះអាចជំរុញពាណិជ្ជកម្មរវាងអង់គ្លេស និងឥណ្ឌាប្រមាណ២៥,៥ ប៊ីលានផោនក្នុងមួយឆ្នាំ នៅឆ្នាំ២០៤០ ដោយបន្ថែម៤,៨ ប៊ីលានផោនដល់សេដ្ឋកិច្ចអង់គ្លេស។ ប្រភព៖ BBC

គណៈកម្មាធិការទទួលបន្ទុកប្រកចូលទីផ្សារ ប្រារព្ធខួបលើកទី ៣០ ចំពេលមានភាពតានតឹងពាណិជ្ជកម្ម

គណៈកម្មាធិការទទួលបន្ទុកប្រកចូលទីផ្សារ (CMA) របស់ WTO បានប្រារព្ធខួបលើកទី៣០ របស់ខ្លួន ដោយលើកឡើងពីសមិទ្ធិផលនានា ដូចជាការពង្រឹងតម្លាភាពក្នុងពន្ធគយ និងការទិន្នន័យពាណិជ្ជកម្ម។ សមាជិកបានពិនិត្យឡើងវិញនូវកង្វល់ពាណិជ្ជកម្មចំនួន៣៣ និងបានអនុម័តរបាយការណ៍ស្តីពីភាពធន់នៃខ្សែប្រវាក់ផ្គត់ផ្គង់។ វឌ្ឍនភាពត្រូវបានកត់សម្គាល់លើប្រព័ន្ធសុខដុមនីយកម្មលេខកូដថ្មី សម្រាប់វ៉ាក់សាំង ដែលជាកិច្ចខិតខំប្រឹងប្រែងរួមគ្នាជាមួយអង្គការសុខភាពពិភពលោក និងអង្គការគយពិភពលោក។ ភាពតានតឹងពាណិជ្ជកម្មត្រូវបានយកមកពិភាក្សា រួមទាំងការព្រួយបារម្ភអំពីបទប្បញ្ញត្តិ នៃការកាប់បំផ្លាញព្រៃឈើរបស់សហភាពអឺរ៉ុប និងការបែកខ្ញែកពាណិជ្ជកម្មសកល។ បញ្ហាពាណិជ្ជកម្មថ្មីចំនួនប្រាំបីត្រូវបានត្រូវលើកឡើង ដែលគ្របដណ្តប់លើផលិតផលដូចជា គ្រាប់កាហ្វេ សារធាតុរ៉ែ និងទំនិញឱសថ។ ប្រភព៖ WTO

ការរឹតត្បិតការនាំចេញលើវត្ថុធាតុដើមកម្រកើនឡើងខ្លាំង ចំពេលមានតម្រូវការកើនឡើង

ទិន្នន័យថ្មីរបស់ អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) បានបង្ហាញពីការកើនឡើងយ៉ាងខ្លាំង នៃការដាក់កំហិតលើការនាំចេញលើវត្ថុធាតុដើមសំខាន់ៗ ដោយសារតែការផ្លាស់ប្តូរទៅរកសេដ្ឋកិច្ចបៃតង និងឌីជីថល និងកង្វល់សន្តិសុខសេដ្ឋកិច្ច។ នៅចុងឆ្នាំ២០២៣ ផលិតផលរ៉ែថ្មីជាង ៥00ប្រភេទ ប្រឈមមុខនឹងការរឹតត្បិតលើការនាំចេញ - ច្រើនជាងទ្វេដងនៃអត្រាកំណើននៃឆ្នាំ២០២២។ សារពើភ័ណ្ឌ OECD ឆ្នាំ២០២៥ គ្របដណ្តប់លើទំនិញឧស្សាហកម្មចំនួន៦៥ ប្រភេទ លើ៨២ ប្រទេស និងបង្ហាញពីការកើនឡើងចំនួន ៥ដងនៃការរឹតត្បិតចាប់តាំងពីឆ្នាំ២០០៩។ ប្រទេសចំនួន៧ រួមទាំងប្រទេសចិន និងរុស្ស៊ីបានដាក់ការរឹតត្បិតថ្មីកើនឡើងចំនួន៩៤% នៃឆ្នាំ ២០២៣ ។ កាកសំណល់ត្រូវបានរឹតត្បិតខ្លាំងបំផុត ប៉ុន្តែ កំណត់តែលើប្រភេទរ៉ែដែក និងសារធាតុរ៉ែផ្សេងៗ ទៀត ដូចជា cobalt និងកម្រ ដែលកំពុងកើនឡើង។ បច្ចុប្បន្ននេះ វិធានការនេះមានការកើនឡើងកាន់តែខ្លាំង រួមមានការហាមឃាត់ និងការដាក់កូតាដែលឆ្លុះបញ្ចាំងពីយុទ្ធសាស្ត្រជាតិកាន់ខ្លាំង ក្នុងការរក្សាតម្លៃធនធានសំខាន់ៗ និងគ្រប់គ្រងខ្សែប្រវាក់ផ្គត់ផ្គង់នៅក្នុងប្រទេសរបស់ខ្លួន។ *ប្រភព៖ OECD*

ផែនការធំរបស់អាស៊ាន ឆ្នាំ២០៤៥ ប្រឈមនឹងពន្ធគយ និងការអនុវត្តរបស់ប្រធានាធិបតី ត្រាំ

ផែនការធំឆ្នាំ២០៤៥ របស់អាស៊ានប្រឈមមុខនឹងបញ្ហាពន្ធគយ និងការអនុវត្តរបស់ប្រធានាធិបតី ត្រាំ។ សមាជិកនៃប្លុកអាស៊ានបានដាក់ចេញនូវផែនការធំមួយ ដើម្បីក្លាយជាប្រទេសដែលមានសេដ្ឋកិច្ចធំជាងគេទីបួនរបស់ពិភពលោក នៅឆ្នាំ២០៤៥ ប៉ុន្តែ អ្នកវិភាគព្រមានថាអាស៊ានត្រូវតែដោះស្រាយលើរបាំងពាណិជ្ជកម្ម ដែលបានចាក់ឫសយ៉ាងជ្រៅ បញ្ហាប្រឈមការអនុវត្តក្នុងស្រុក និងការផ្លាស់ប្តូរសណ្តាប់ធ្នាប់ពាណិជ្ជកម្មសកល។ ការដំឡើងកម្រិត នូវកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន (ATIGA) មានគោលបំណងជំរុញពាណិជ្ជកម្មក្នុងតំបន់អាស៊ានបន្ថែមទៀត ដោយលុបបំបាត់កាតព្វកិច្ចដែលនៅសល់ និងដកចេញរបាំងមិនមែនពន្ធ។ សមាជិកអាស៊ាន រងផលប៉ះពាល់ខ្លាំងដោយពន្ធរបស់ប្រធានាធិបតី ត្រាំ។ អ្នកវិភាគព្រមានថា ការប្រជែងគ្នារបស់សមាជិកអាស៊ាន សម្រាប់ការទទួលបានកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីជាមួយអាម៉េរិក អាចធ្វើឱ្យខូចដល់ឯកភាពក្នុងតំបន់។ សមាហរណកម្មក្នុងអាស៊ានមានភាពយឺតយ៉ាវដោយសារភាពខុសគ្នានៃសេដ្ឋកិច្ច និងអាស៊ានខ្វះអាជ្ញាធរកណ្តាល ហើយកតិកាសញ្ញាសេដ្ឋកិច្ចចំនួន២៤ មិនទាន់ត្រូវបានអនុម័តទេ។ *ប្រភព៖ South China Morning Post*

A Step Back from The Brink for The Global Economy

A new US-China trade agreement sharply reduces tariffs, easing global economic tensions after recent policy shocks. The deal includes a 30% US tariff on Chinese exports and 10% on US exports to China, effective for at least 90 days. This, along with paused tariffs on other countries, has stabilized markets. However, economic uncertainty remains high. The IMF cut global growth forecasts to 2.8%. Despite market relief, the global economy still faces challenges, including rising debt and weakened consumer sentiment. ***Source: World Economic Forum***

Redefining Risk in The Dynamic Era of Global Trade

As global trade becomes more entwined with economic and geopolitical pressures, trade professionals need to examine the key risk factors in critical areas of import and export workflows and global supply chains. The current wave of tariffs, especially against Chinese imports, is accelerating decoupling and increasing sourcing costs, now the number one risk. Importers must model duties and adapt strategies amid changing tariffs. Trade lane analysis, sub-tier mapping, authentication of origin documents, and understanding counterparty risk are vital. Free trade zones offer benefits but carry risks outside the U.S. Technology, including real-time data, biometric identifiers, and document authentication, is essential to ensure transparency and due diligence. ***Source: THOMSONREUTERS***

Four Things You Need to Know About UK-India Trade Deal

The UK and India have agreed a major trade deal to lower tariffs on goods like clothing, food, jewellery, cars, whisky, and medical devices. British firms will also gain access to Indian services contracts. While the changes won't be immediate, the UK government expects cheaper prices, more choice, and business growth over time. Whisky tariffs in India will fall from 150% to 40% over ten years, and car tariffs from over 100% to 10%. The deal may boost UK-India trade by £25.5bn annually by 2040, adding £4.8bn to the UK economy. ***Source: BBC***

Committee on Market Access Marks 30th Anniversary Amid Trade Tensions

The WTO's Committee on Market Access (CMA) marked its 30th anniversary, highlighting achievements such as enhanced transparency in tariffs and trade data. Members reviewed 33 trade concerns and adopted a report on supply chain resilience. Progress was noted on new Harmonized System codes for vaccines, a joint effort with WHO and WCO. Trade tensions were addressed, including concerns over EU deforestation regulations and global trade fragmentation. Eight new trade issues were raised, covering products like coffee beans, minerals, and pharmaceutical goods. ***Source: WTO***

Export Restrictions on Critical Raw Materials Rise Sharply Amid Growing Demand

New OECD data reveals a sharp rise in export restrictions on critical raw materials, driven by the green and digital transitions and economic security concerns. By the end of 2023, over 500 new raw mineral products faced restrictions—more than double the growth rate of 2022. The 2025 OECD Inventory covers 65 industrial commodities across 82 countries and shows a fivefold increase in restrictions since 2009. Seven countries, including China and Russia, imposed 94% of new restrictions in 2023. Waste and scrap remain the most restricted, but limits on ores and minerals like cobalt and rare earths are rising. Measures now increasingly include prohibitions and quotas, reflecting more assertive national strategies to retain resource value and control supply chains. ***Source: OECD***

SEAN's Ambitious 2045 Plan Faces Trump Tariffs and Implementation Woes

Asean's ambitious 2045 plan faces Trump tariffs and implementation woes. Members of the Asean bloc have laid out an ambitious plan to become the world's fourth-largest economy by 2045, but analysts warn the region must first overcome deep-rooted trade barriers, domestic implementation woes and a shifting global trade order. An upgraded Asean Trade in Goods Agreement (ATIGA) aims to further boost intra-Asean trade by eliminating remaining duties and removing non-tariff barriers. Asean member states were the hardest hit by Trump's tariffs; analysts warn Asean's scramble for bilateral trade deals with Washington could undermine regional unity. Integration within Asean has been slow due to differences in economies, and Asean lacks a central authority; 24 economic pacts have not been enacted. ***Source: South China Morning Post***

About the iTrade

iTrade Bulletin is an e-publication by the Trade Training and Research Institute of the Ministry of Commerce. This monthly bulletin provides brief updates on specific issues in Cambodia, the regions and the world.

This knowledge-sharing through scientific researches in the multifaceted areas aims to highlight current trade news & statistics relevant to all social stakeholders.

Announcement

Academicians, researchers, students and public are welcome to contribute their academic works, on all disciplines and topics of relevant interest to trade, to the next publication of the iTrade Bulletin.

Topics Covered:

•International trade and logistics / trade laws;
•Digital economy / e-commerce;
•Economics and economic laws;
•Value added supply chains and logistics; and
•Facilitate the green business transition

Categories:

•Research articles
•Case reports
•Policy Briefs

Trade Training and Research Institute

Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA

ttri.moc | www.ttri.moc.gov.kh | @ttrimoccambodia